**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ជ.ស.ដ )
ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 18-Nov-2011, 13:11
CMS/CFO: Kauv Keoratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច. ឬ អង្គជំនុំជម្រះសាលាដំបូង **សាធារណៈ/Public**
ស្ថានភាពចំណាត់ថ្នាក់ឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបញ្ជាក់ពីវិសាលភាព នៃសវនាការដំបូង**

| **ដាក់ដោយ៖** | **ផ្ញើជូន៖** |
|---|---|
| សហមេធាវីការពារក្តី ៖ | **ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ៖** |
| លោក អាង ឧត្តម | **ចៅក្រម និល ណុន** |
| លោក Michael G. KARNAVAS | **ចៅក្រម យ៉ូរ ឧត្តរា** |
| | **ចៅក្រម យ៉ា សុខន** |
| | **ចៅក្រម** Silvia CARTWRIGHT |
| | **ចៅក្រម** Jean-Marc LA VERGNE |
| | **ចៅក្រមបម្រុង ធូ មុនី** |
| | **ចៅក្រមបម្រុង** Claudia FENZ |

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្ដីរបស់គាត់ ("មេធាវីការពារក្ដី") តទៅនេះសូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង ("សំណើ")[១]។ ចម្លើយតបនេះត្រូវធ្វើឡើងជាចាំបាច់ ពីព្រោះសហព្រះរាជអាជ្ញាបានប្រើប្រាស់សំណើនេះជាវិធីមួយដើម្បីស្នើយ៉ាងទទូចឲ្យពិចារណាជាលើកទីពីរលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី[២]។ សំណើដំបូងរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យពិចារណាឡើងវិញ ត្រូវបានបដិសេធ ដោយអង្គជំនុំជម្រះសាលាដំបូង[៣]រួចហើយ។ នេះគឺជាការបំពានដល់ដំណើរការនីតិវិធី។

I. **ចម្លើយតប**

ក. សេចក្ដីសង្កេតបឋម

១. មុននឹងធ្វើការពិភាក្សាអំពីខ្លឹមសារនៃសំណើ មេធាវីការពារក្ដីសូមបំភ្លឺបញ្ហាបឋមមួយជាមុនសិន។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការដំបូងដែលបានធ្វើឡើងនៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ភាគីទាំងអស់ត្រូវបាន "ជំរុញឲ្យលើកឡើងអំពីការព្រួយបារម្ភ ឬស្នើសុំព័ត៌មានជាលក្ខណៈក្រៅផ្លូវការពីមន្ត្រីច្បាប់ជាន់ខ្ពស់ [("មន្ត្រីច្បាប់ជាន់ខ្ពស់")] របស់អង្គជំនុំជម្រះសាលាដំបូងបាន ប្រសិនបើអាចធ្វើទៅបាន។ ក្នុងកម្រិតដែលអាចធ្វើទៅបាន និងសមស្រប វិធីនេះគួរយកមកប្រើប្រាស់ជំនួសឲ្យការដាក់សំណើសុំដែលគ្រាន់តែធ្វើការស្វែងរកព័ត៌មាន ឬលើកជាសំណួរ"[៤]។ "ការលើក

---

[១] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E124/9។

[២] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E124 ("ដីកាបំបែកកិច្ចដំណើរការនីតិវិធី")។ សហព្រះរាជអាជ្ញាបានធ្វើសំណើសុំពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។ សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញលើលក្ខខណ្ឌនៃ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E124/1 ("សំណើសុំឲ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី") ។

[៣] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/7។

[៤] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E1/2.1, ទំព័រ ១០។

ទឹកចិត្ត" នេះត្រូវបានធ្វើឡើងស្របគ្នានឹងការព្រមានមួយថា "កន្លងមក អង្គជំនុំជម្រះធ្លាប់បានផ្តល់អនុសាសន៍មិនឱ្យផ្តល់ប្រាក់កម្រៃចំពោះការដាក់ឯកសារមួយចំនួន ដែលអង្គជំនុំជម្រះយល់ឃើញថាមិនមានមូលដ្ឋានផ្លូវច្បាប់ និងគ្រាន់តែជាការបន្ថែមបន្ទុកមកអង្គជំនុំជម្រះ និងសេវាបកប្រែភាសាប៉ុណ្ណោះ។ អង្គជំនុំជម្រះសូមរំឭកដល់មេធាវីអំពីកាតព្វកិច្ចរបស់ខ្លួន ផ្អែកតាមវិធាន ២៤(៤)"[៥]។ មេធាវីការពារក្តីយល់ឃើញថា ការលើកទឹកចិត្តដែលត្រូវបានធ្វើឡើងស្របគ្នានឹងការព្រមានដាក់ទណ្ឌកម្មដែលត្រូវតែគោរពតាមនេះ គឺមានន័យស្មើនឹងសេចក្តីណែនាំ (សេចក្តីបង្គាប់) ដាច់ខាតមួយរបស់អង្គជំនុំជម្រះសាលាដំបូង។ ការលើកទឹកចិត្តនេះត្រូវបានលើកមកបញ្ជាក់ម្តងហើយម្តងទៀតជាច្រើនដងដោយអង្គជំនុំជម្រះសាលាដំបូង[៦]។ ចៅក្រម Cartwright បានលើកទឹក

---

[៥] ដូចខាងលើ។

[៦] "អង្គជំនុំជម្រះធ្វើការក្រើនរំឭកដល់ក្រុមមេធាវីការពារក្តីរបស់ អៀង សារី នូវសេចក្តីបង្គាប់ដូចតទៅនេះដែលសេចក្តីបង្គាប់ទាំងនេះត្រូវបានប្រកាសក្នុងកិច្ចប្រជុំរៀបចំសវនាការថា "ដើម្បីកាត់បន្ថយការបកប្រែភាសា និងបញ្ហាប្រឈមផ្សេងៗទៀត និងដើម្បីធានាឱ្យមានការរៀបចំសវនាការមានប្រសិទ្ធភាពនោះ ប្រសិនបើអាចធ្វើទៅបាន ភាគីនានាត្រូវបានជំរុញឱ្យលើកឡើងអំពីការព្រួយបារម្ភ ឬស្នើសុំព័ត៌មានជាលក្ខណៈក្រៅផ្លូវការពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបាន។ ក្នុងកម្រិតដែលអាចធ្វើទៅបាន និងសមស្រប វិធីនេះគួរយកមកប្រើប្រាស់ជំនួសឱ្យការដាក់សំណើសុំដែលគ្រាន់តែធ្វើការស្វែងរកព័ត៌មាន ឬលើកជាសំណួរនោះ។ កន្លងមក អង្គជំនុំជម្រះធ្លាប់បានផ្តល់អនុសាសន៍មិនឱ្យផ្តល់ប្រាក់កម្រៃចំពោះការដាក់ឯកសារមួយចំនួនដែលអង្គជំនុំជម្រះយល់ឃើញថា មិនមានមូលដ្ឋានផ្លូវច្បាប់ នឹងគ្រាន់តែជាការបន្ថែមបន្ទុកមកអង្គជំនុំជម្រះ និងសេវាបកប្រែភាសាប៉ុណ្ណោះ។ អង្គជំនុំជម្រះសូមរំឭកដល់មេធាវីអំពីកាតព្វកិច្ចរបស់ខ្លួន ផ្អែកតាមវិធាន ២៤(៤)""។ អនុស្សរណៈពីប្រធានអង្គជំនុំជម្រះសាលាដំបូង ចៅក្រម និល ណុន ផ្ញើជូនភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ដែលមានកម្មវត្ថុថា "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំ លេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E74។ "ភាគីទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យលើកឡើងនូវបញ្ហានានាដែលនៅសេសសល់ជាលក្ខណៈក្រៅផ្លូវការមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងឱ្យបានកាន់តែឆាប់តាមតែអាចធ្វើបាន និងមិនឱ្យហួសថ្ងៃអង្គារ ទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១"។ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើជូនភាគីទាំងអស់ក្នុងសំណុំរឿង ០០២, ដែលមានកម្មវត្ថុថា "ការប្រាស្រ័យទាក់ទងនឹងភាគីទាំងអស់ ក្នុងសំណុំរឿង ០០២ ទាក់ទងនឹងការកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តី នៃសំណុំរឿង ០០២ និងព័ត៌មានមុនពេលបើកសវនាការ នៅថ្ងៃទី ១៩ ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១" ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ (បញ្ជាក់បន្ថែម)។ *សូមអានផងដែរ* "យើងក៏សូមស្នើឱ្យលោកយកឈ្មោះចៅក្រមចេញពីការទំនាក់ទំនងដូចនេះនៅពេលអនាគត ដែលការធ្វើដូចនេះគឺជាការបំពានយ៉ាងច្បាស់លាស់ដល់សេចក្តីណែនាំមុនៗដល់ភាគីទាំងអស់"។ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើជូនសហព្រះរាជអាជ្ញា

ចិត្តសហមេធាវីការពារក្ដីអន្តរជាតិរបស់ អៀង សារី Michael G. Karnavas ឱ្យធ្វើការទំនាក់ទំនងជាលក្ខណៈក្រៅផ្លូវការជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់[៧] នៅពេលមានការទំនាក់ទំនងត្រូវបានគេជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូង (តាមរយៈការចម្លងជូនទៅអង្គជំនុំជម្រះសាលាដំបូងតាមសារអេឡិចត្រូនិក) ដែលថា មន្ត្រីច្បាប់ជាន់ខ្ពស់បានប្រាប់ព័ត៌មាន ទៅភាគី និងទៅបុគ្គលមិនមែនជាភាគីមួយចំនួនតែប៉ុណ្ណោះ ជាលក្ខណៈក្រៅផ្លូវការអំពីការចាប់ផ្ដើមសវនាការ (ផ្ទុយទៅនឹងកាតព្វកិច្ចដែលខ្លួនត្រូវតែប្រាប់ព័ត៌មានទៅភាគីទាំងអស់)[៨]។

២. បើទោះបីមេធាវីការពារក្ដីចាត់ទុកថា ការប្រាស្រ័យទាក់ទងជាលក្ខណៈក្រៅផ្លូវការជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់ទាក់ទងនឹងបញ្ហានីតិវិធី និងផ្លូវច្បាប់គឺជាការមិនសមស្រប និងខ្វះតម្លាភាព ក៏ដោយក៏មេធាវីការពារក្ដីបានគោរពការលើកទឹកចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង។ ដើម្បីស្មើភាពគ្នា និងតម្លាភាព មេធាវីការពារក្ដីសូមលើកយកសំណើមុនៗរបស់ខ្លួនផ្ញើទៅអង្គជំនុំជម្រះសាលាដំបូង[៩]

---

ដែលមានកម្មវត្ថុថា "ការសុំការអនុញ្ញាតរបស់សហព្រះរាជអាជ្ញាដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី និង នួន ជា ចំពោះសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញលើពាក្យដីកាបំបែកដំណើរការនីតិវិធីក្នុងការបកប្រែជាភាសាខ្មែរ" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១; "ខ្ញុំបានបញ្ជាក់ពីពេលកន្លងទៅហើយថា ខ្ញុំជាអ្នកទទួលបន្ទុកសម្រាប់ការប្រាស្រ័យទាក់ទងរបស់ភាគីទាំងអស់ជាមួយនឹងអង្គជំនុំជម្រះ។ អាស្រ័យហេតុនេះ សូមបញ្ឈប់ការផ្ញើសារអេឡិចត្រូនិកដូចនេះទៅចៅក្រមអង្គជំនុំជម្រះសាលាដំបូង"។ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើជូន Michael G. Karnavas ដែលមានកម្មវត្ថុថា "កាលបរិច្ឆេទចាប់ផ្ដើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១។

៧ "សូមជម្រាបលោក Karnavas ថា ចៅក្រមទាំងអស់មានការបារម្ភថា គាត់នៅតែបន្តបញ្ចូលឈ្មោះចៅក្រមនៅក្នុងលិខិតឆ្លើយឆ្លងរបស់គាត់ ដោយគាត់ធ្វើយុត្តិកម្មថា ការធ្វើបែបនេះជាការសំខាន់។ ការណ៍ដែលគាត់ប្រើប្រាស់មធ្យោបាយផ្ញើលិខិតឆ្លើយឆ្លងទាក់ទងដោយផ្ទាល់បែបនេះមិនមែនជាការត្រឹមត្រូវទេ នៅពេលដែលគេដឹងច្បាស់ថា អ្នកត្រូវបាន អ.ជ.ស.ដ ប្រាប់ឱ្យទាក់ទងជាលក្ខណៈក្រៅផ្លូវការជាមួយភាគីនានាបែបនេះ។ ឬយ៉ាងហោចណាស់ ក៏វាជាការយល់ឃើញរបស់ខ្ញុំម្នាក់ដែរ!" សារអេឡិចត្រូនិករបស់ចៅក្រម Cartwright ផ្ញើជូនលោក Michael G. Karnavas ដែលមានកម្មវត្ថុថា "កាលបរិច្ឆេទចាប់ផ្ដើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១។

៨ សារអេឡិចត្រូនិកពី Michael G. Karnavas ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "កាលបរិច្ឆេទចាប់ផ្ដើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១។

៩ មើលលិខិតរបស់មេធាវីការពារក្ដី អៀង សារី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "ការកំណត់កាលបរិច្ឆេទសវនាការលើអង្គសេចក្ដី" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់មេធាវីការពារក្ដី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "សំណើសុំការបញ្ជាក់ទាក់ទងនឹងអញ្ញត្រកម្មចំពោះបញ្ញើឯកសាររបស់ការិយាល័យសហព្រះ

ដើម្បីដាក់លិខិតទាំងអស់នេះ[១០] ក្នុងនោះមានសារអេឡិចត្រូនិកទាក់ទងនឹងបញ្ហាដែលអាចជាឧបសគ្គដល់ប្រសិទ្ធភាពនៃដំណាក់កាលដំបូងនៃសវនាការ និងបញ្ហាផ្សេងៗទៀតដែលបានបញ្ជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់ ទៅដាក់នៅក្នុងសំណុំរឿងដើម្បីឲ្យមានកំណត់ត្រាត្រឹមត្រូវ ពេញលេញ និងមានតម្លាភាព។

## ខ. ចម្លើយតបគឺជាសារណាអំពីការស្នើសុំឲ្យពិចារណាឡើងវិញជាលើកទីពីរ

---

រាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់មេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "សំណើសុំព័ត៌មាន ទាក់ទងនឹងអញ្ញត្រកម្មសំខាន់ៗ" ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

១០ ក្រុមមេធាវីការពារក្តីស្នើអង្គជំនុំជម្រះសាលាដំបូងដាក់លិខិតទាំងអស់នេះក្នុងសំណុំរឿង ៖ លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "ការកំណត់កាលបរិច្ឆេទសវនាការលើអង្គសេចក្តី" ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "សំណើសុំពិចារណាឡើងវិញនូវអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុថា "បញ្ជីឈ្មោះសាក្សីសម្រាប់សវនាការដំណាក់កាលដំបូង, កាលបរិច្ឆេទចុងក្រោយក្នុងការដាក់សារណាជំទាស់ទៅនឹងការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសារណា E-109/5", ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "សំណើសុំឯកសារថតចម្លងនៃឯកសារយោងដែលបានដកស្រង់ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "បញ្ហាដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃផ្នែកដំបូងនៃសវនាការលើអង្គសេចក្តី" ថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "សំណើសុំការបញ្ជាក់ទាក់ទងនឹងអញ្ញត្រកម្មចំពោះបញ្ជីឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់ដែលមានកម្មវត្ថុថា "សេចក្តីជូនដំណឹងទាក់ទងនឹងអញ្ញត្រកម្មរបស់ អៀង សារី ចំពោះឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់រយៈពេល ៣ សប្តាហ៍ដំបូងនៃសវនាការ" ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់ ដែលមានកម្មវត្ថុថា "សំណើសុំព័ត៌មានទាក់ទងនឹងអញ្ញត្រកម្មដំបូងសំខាន់ៗ ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងលិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់, ដែលមានកម្មវត្ថុថា "សំណៅថតចម្លងពីឯកសារយោង ដែលបានដកស្រង់ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

៣. សំណើនេះគឺការប៉ុនប៉ងដោយមានការបិទបាំងតិចតួចរបស់សហព្រះរាជអាជ្ញា ក្នុងការស្នើឲ្យមានការពិចារណាឡើងវិញ លើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី[១១]។ សហព្រះរាជអាជ្ញាកំពុងប្រើប្រាស់សំណើនេះជាវិធីមួយ ដើម្បីពង្រីកវិសាលភាពនៃសវនាការដំបូងដើម្បីរួមបញ្ចូលរាល់បទចោទទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយតែម្តង[១២] ដែលជាសំណើធ្វើឲ្យដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលែងមានន័យ។ ដូចគ្នានេះដែរ នៅក្នុងសំណើរបស់ខ្លួនសុំឲ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី សហព្រះរាជអាជ្ញាបានស្នើសុំឲ្យពង្រីកវិសាលភាពនៃសវនាការលើកដំបូង[១៣]។

៤. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយ លើសំណើសុំឲ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ[១៤]។ ការពិចារណាជាលើកទីពីរមិនត្រូវបានគេរំពឹងទុកថានឹងកើតមានឡើងនៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ទេ។ ទោះបីជាមេធាវីការពារក្តីឯកភាពជាមួយនឹងសហព្រះរាជអាជ្ញាថា ចាំបាច់ត្រូវការការបញ្ជាក់ជាបន្ទាន់លើបញ្ហាសំខាន់ៗទាក់ទងនឹងការគ្រប់គ្រងសវនាការក៏ដោយ ក៏វាជាការបំពានដល់ដំណើរការនីតិវិធីក្នុងការស្វែងរកការបញ្ជាក់ដោយការដាក់សារណា ដែលប៉ុនប៉ងឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញលើបញ្ហានានាដែលបានសម្រេចរួចហើយនោះ។

៥. មេធាវីការពារក្តីបានស្នើសុំឲ្យមានកិច្ចប្រជុំរៀបចំសវនាការ ដើម្បីដោះស្រាយបញ្ហានានាដែលពុំ

---

[១១] អង្គជំនុំជម្រះសាលាដំបូងហាក់បីដូចជាទទួលស្គាល់ថា សំណើដែលបានធ្វើឡើងទាក់ទងនឹងដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលជាចំនួនឯកសារក្នុងសំណើគឺជាប្រភេទឯកសារដូចគ្នានឹងដីកាបំបែកកិច្ចដំណើរការនីតិវិធី ឯកសារលេខ E124។

[១២] សំណើ កថាខណ្ឌ ១៣។

[១៣] សំណើសុំពិចារណាឡើងវិញលើដីកាបំបែកដំណើរការនីតិវិធី កថាខណ្ឌ ៣៦ ដល់ ៤៤។

[១៤] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (E124/2) និងសំណើសុំពាក់ព័ន្ធនានា និងឧបសម្ព័ន្ធ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E124/7។

ទាន់បានដោះស្រាយនៅឡើយ[១៥]។ គួរឲ្យសោកស្តាយ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចមិនប្រើប្រាស់ជំនាញ និងចំណេះដឹងដែលភាគីមួយចំនួន បានប្រមែប្រមូលក្នុងរយៈពេលវេលាយ៉ាងយូរមកហើយ និងមិនប្រើប្រាស់ការអនុវត្តដែលមាននៅចំពោះមុខអង្គជំនុំជម្រះអន្តរជាតិនោះទេ ក្នុងពេលអង្គជំនុំជម្រះសាលាដំបូងដោះស្រាយបញ្ហាសំណុំរឿងធំ និងស្មុគស្មាញ ដូចជាសំណុំរឿង ០០២ នេះ។

៦. ក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី ជំនួសឲ្យការដាក់សំណើមិនសមស្របនានាសុំឲ្យពិចារណាឡើងវិញជាលើកទីពីរ ឬក៏សំណើសមស្របស្នើសុំធ្វើការបញ្ជាក់ សហព្រះរាជអាជ្ញាគួរតែបន្ទរួមគ្នាជាមួយនឹងក្រុមមេធាវីការពារក្តី ជំរុញអង្គជំនុំជម្រះសាលាដំបូង[១៦] ឲ្យរៀបចំកិច្ចប្រជុំរៀបចំសវនាការសំខាន់ៗ ដើម្បីពិនិត្យឲ្យបានល្អិតល្អន់ និងដោះស្រាយឲ្យបានច្បាស់លាស់ និងជាក់លាក់ នូវបញ្ហាដែលមិនទាន់បានដោះស្រាយ ឬបញ្ហាដែលពុំច្បាស់លាស់ទាំងឡាយ។

## II. សេចក្តីសន្និដ្ឋាន

៧. ប្រសិនបើមេធាវីការពារក្តីជាភាគីស្នើសុំឲ្យមានការពិចារណាឡើងវិញដូចវិញនោះ មេធាវីការពារក្តីអាចនឹងទទួលរងការដាក់ទណ្ឌកម្មរួចទៅហើយ[១៧]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេច

---

[១៥] *អាន* ការគាំទ្ររបស់ អៀង សារី ចំពោះសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យមានកិច្ចប្រជុំស្តីពីការរៀបចំសវនាការ និងការប្រជុំទៀងទាត់ស្តីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង ០០២ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E132/1; លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូន មន្ត្រីច្បាប់ជាន់ខ្ពស់ ដែលមានកម្មវត្ថុថា "សំណើសុំពិចារណាឡើងវិញលើអនុស្សរណៈនៃអង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុថា "បញ្ជីឈ្មោះសាក្សីសម្រាប់សវនាការដំណាក់កាលដំបូង, កាលបរិច្ឆេទចុងក្រោយក្នុងការដាក់សារណាជំទាស់ទៅនឹងការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសារណា E-109/5"", ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១ និង លិខិតរបស់ក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ ដែលមានកម្មវត្ថុថា "កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តី" ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។

[១៦] សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យមានការប្រជុំមួយស្តីពីការរៀបចំសវនាការ និងការប្រជុំទៀងទាត់នានាស្តីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង ០០២ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E132។

[១៧] មានម្តងនោះមេធាវីការពារក្តីបានដាក់សេចក្តីសង្កេតចំពោះចម្លើយតបមួយ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថាការដាក់ដូចនេះចាំបាច់ត្រូវមាន "សំណើឆ្លើយតប" និង "ការដាក់ឯកសារដូចនេះទៀតនាពេលអនាគត បើគ្មានការអនុញ្ញាតទេ នឹងត្រូវដកចេញពីសំណុំរឿង ដោយធ្វើការណែនាំទៅអង្គភាពគាំពារការការពារក្តីថា ការងារដូចនេះនឹងមិន

ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបញ្ជាក់ពីវិសាលភាព

ទទួលយកសំណូមពររបស់សហព្រះរាជអាជ្ញានោះ សកម្មភាពរបស់អង្គជំនុំជម្រះសាលាដំបូងនឹងបង្ហាញពីការសម្រេចមួយដែលទោរទន់សហព្រះរាជអាជ្ញាខ្លាំងជាងមេធាវីការពារក្តី។ មេធាវីការពារក្តី មើលមិនឃើញពីផលប្រយោជន៍ក្នុងការឆ្លើយតបទៅនឹងខ្លឹមសាររបស់សំណើនេះឡើយ ពីព្រោះអង្គជំនុំជម្រះសាលាដំបូង បានសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរួចហើយ។ ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលស្គាល់សំណូមពររបស់សហព្រះរាជអាជ្ញា យើងសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងធ្វើការច្រានចោលដីការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងជំនុំជម្រះសំណុំរឿង ០០២ ដូចមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ *ទាំងស្រុង* តែម្តង។

**អាស្រ័យហេតុនេះ** ដោយផ្អែកលើមូលហេតុទាំងអស់ខាងលើ ក្រុមការពារក្តីស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា ៖

ក. **ច្រានចោល** សំណើសុំឲ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី

ខ. **កំណត់កាលបរិច្ឆេទ** សម្រាប់កិច្ចប្រជុំរៀបចំសវនាការដោយមានកំណត់ត្រាកិច្ចប្រជុំពេញលេញដោយមានការចូលរួមពីភាគីទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង និង

គ. **ដាក់** លិខិត និងសារអេឡិចត្រូនិកខាងលើដែលបានផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ទៅក្នុងសំណុំរឿង។

សូមដាក់ជូនចម្លើយតបនេះដោយគោរពពី ៖

| អាង ឧត្តម | Michael G. KARNAVAS |
|---|---|

សហមេធាវីការពារក្តី អៀង សារី

ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៦ ខែ **វិច្ឆិកា** ឆ្នាំ ២០១១

---

ទទួលបានប្រាក់កម្រៃឡើយ”។ អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន ផ្ញើជូនភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ដែលមានកម្មវត្ថុថា “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដែលមានឯកសារលេខ E91/2, E95/7, E99/1/1, E100/4/1, E101/3, E114/2, E119 និងការឆ្លើយតបទៅនឹងសំណើសុំឲ្យមានការណែនាំទូទៅអំពីការឆ្លើយតប (ឯកសារលេខ E112) ចុះថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០១១ ឯកសារលេខ E126។